ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួប
ប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក
******

នៅរសៀលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង១៦:០០ នៅទីស្តីការក្រសួង **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកស្រី Maria Nenette A. Motus ប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (International Organization for Migration) ប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងការស្វាគមន៍ចំពោះដំណើរទស្សនកិច្ចរបស់លោកស្រីមកកាន់កម្ពុជា និងការអបអរសាទរចំពោះការតែងតាំងលោកស្រីជាប្រធានរបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ហើយក៏បានវាយតម្លៃខ្ពស់ចំពោះបទពិសោធន៍ និងជោគជ័យដែលលោកស្រីសម្រេចបាននៅក្នុងការងារពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សំខាន់របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ក្នុងការជួយដល់បណ្តាប្រទេសសមាជិកលើបញ្ហាទេសន្តរប្រវេសន៍ និងជនទេសន្តរប្រវេសន៍ ហើយបានសម្តែងនូវការអបអរសាទរចំពោះអង្គការអន្តរជាតិទេសន្តរប្រវេសន៍ ដែលបានក្លាយទៅជាទីភ្នាក់ងារទេសន្តរប្រវេសន៍របស់អង្គការសហប្រជាជាតិ កាលពីខែកញ្ញា ឆ្នាំ២០១៦ កន្លងមកនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានរំលឹកឡើងវិញអំពីកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភដ៏សកម្មរបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ ចំពោះប្រជាជនកម្ពុជាដែលបានភៀសខ្លួនក្នុងដំណាក់កាលកើតមានសង្គ្រាមនៅកម្ពុជា ក៏ដូចជាការវិលត្រឡប់របស់ពួកគេមកកាន់មាតុប្រទេសវិញ បន្ទាប់ពីមានសន្តិភាព។

លោកស្រី Motus បានជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី ដោយរំលឹកឡើងវិញពីការបំពេញការងាររបស់លោកស្រីជាប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំនៅកម្ពុជា ក្នុងឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០២ ហើយលោកស្រីបានលើកឡើងពីមនោសញ្ចេតនារីករាយរបស់លោកស្រី ដែលបានត្រឡប់មកកាន់កម្ពុជា ដើម្បីបន្តកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជានៅលើបញ្ហាទេសន្តរប្រវេសន៍នេះ។ លោកស្រីបានថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល លើការបំពេញភារកិច្ចការងាររបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍។ លោកស្រីបានអះអាងថា អង្គការអន្តរជាតិទេសន្តរប្រវេសន៍ នឹងបន្តកិច្ចសហប្រតិបត្តិការនិងពង្រឹងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅលើការងារទេសន្តរប្រវេសន៍នេះ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបជូន លោកស្រី Motus ដោយត្រួសៗអំពីវត្តមានរបស់ពលករកម្ពុជានៅប្រទេសថៃដែលមានចំនួនជាងមួយលាននាក់ ហើយឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា នៅក្នុងនោះ មានប្រមានមួយភាគបីប៉ុណ្ណោះដែលជាពលករស្របច្បាប់ ហើយចំណែកឯពីរភាគបីទៀត គឺជាពលករនៅមិនទាន់មានលក្ខណៈស្របច្បាប់នៅឡើយ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការធ្វើឲ្យពលករខ្មែរនៅប្រទេសថៃទាំងអស់ទទួលបាននូវស្ថានភាពស្របច្បាប់ក្នុងការរស់នៅ និងបំពេញការងារនៅប្រទេសថៃ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានលើកឡើងពីការខិតខំរបស់ស្ថានទូត/ស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃ កូរ៉េខាងត្បូង ម៉ាឡេស៊ី ចិន ជប៉ុន។ល។ ក្នុងការជួយដោះស្រាយរាល់បញ្ហានិងការលំបាករបស់ពលករ/ពលការិនី និងស្ត្រីខ្មែររងគ្រោះដោយការជួញដូរមនុស្ស ហើយបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរបស់អង្គការ IOM លើបញ្ហានេះ ពិសេសគឺការជួយផ្តល់សំបុត្រយន្តហោះជូនដល់ពលករនិងស្ត្រីខ្មែររងគ្រោះ ក្នុងការធ្វើមាតុភូមិនិវត្តន៍ត្រលប់មកកាន់កម្ពុជាវិញ។

លោកស្រី Motus បានអះអាងជូនឯកឧត្តមទេសរដ្ឋមន្ត្រីអំពីការប្តេជ្ញាចិត្តរបស់អង្គការ IOM ប្រចាំនៅកម្ពុជា ក៏ដូចជារបស់លោកស្រីផ្ទាល់ដែលជាប្រធានអង្គការ IOM ប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក និងរបស់អង្គការIOMទាំងមូល ក្នុងការបន្តកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយរាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាទេសន្តរ-ប្រវេសន៍ ហើយបានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងការបរទេស ក្នុងការផ្តល់នូវកិច្ចសហប្រតិបត្តិការពេញលេញជាមួយIOM។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៧